# សេចក្តីថ្លែងការណ៍រួម

## ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលជំរុញឱ្យមានការការពារអ្នកសារព័ត៌មាន និងការរាយការណ៍ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈអំឡុងពេលជម្លោះព្រំដែន កម្ពុជា-ថៃ

យើងខ្ញុំ ជាស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលធ្វើការលើសេរីភាពសារព័ត៌មាន ការការពារអ្នកសារព័ត៌មាន ការរាយការណ៍ព័ត៌មានប្រកបដោយវិជ្ជាជីវៈ បានរួមគ្នាចេញសេចក្តីថ្លែងការណ៍នេះ ដែលផ្តោតលើការផ្សព្វផ្សាយព័ត៌មានថ្មីៗទាក់ទងនឹងជម្លោះព្រំដែនរវាងកម្ពុជា-ថៃ និងសុវត្ថិភាពរបស់អ្នកសារព័ត៌មាន ដែលរាយការណ៍ពីតំបន់ជម្លោះនោះ។

យើងខ្ញុំសូមបញ្ជាក់ថា អ្នកសារព័ត៌មានមិនមែនជាគោលដៅនៅក្នុងជម្លោះនោះទេ រួមទាំងជម្លោះប្រដាប់អាវុធផងដែរ។ សុវត្ថិភាព និងឯករាជ្យភាពរបស់ពួកគេត្រូវតែគោរព និងការពារគ្រប់ពេលវេលាជាមួយនឹងកាតព្វកិច្ចរាយការណ៍ចំពោះជម្លោះដែលកើតឡើង ឬបរិយាកាសរាយការណ៍ដ៏រសើបនោះផងដែរ។ យើងសូមជំរុញឱ្យអាជ្ញាធរកម្ពុជា-ថៃ ផ្តល់ព័ត៌មានទាន់ហេតុការណ៍ និងត្រឹមត្រូវសម្រាប់ការផ្សាយព័ត៌មាន ដើម្បីធានាឱ្យបានទាន់ពេលវេលា និងតម្លាភាពក្នុងការទទួលបានព័ត៌មាន ដែលអាចទុកចិត្តបាន និងធានាសុវត្ថិភាព និងសេរីភាពសម្រាប់អ្នកសារព័ត៌មានទាំងអស់ដែលរាយការណ៍អំពីបញ្ហានេះ។

យើងខ្ញុំសូមជំរុញឱ្យភ្នាក់ងារប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ ក្នុងតំបន់ និងក្នុងប្រទេស ប្រកាន់ខ្ជាប់នូវគោលការណ៍នៃការ រាយការណ៍ទូលំទូលាយ មានតុល្យភាព និងមិនលំអៀង ក៏ដូចជាការផ្តល់នូវឧបករណ៍សុវត្ថិភាពសម្រាប់ ការពារដល់បុគ្គលិកផ្នែកគាំទ្រ និងអ្នកសារព័ត៌មានដែលបានរាយការណ៍នៅតំបន់នោះ។

យើងខ្ញុំសង្កេតឃើញថាជម្លោះព្រំដែនរយៈពេលប្រាំថ្ងៃបានឆ្លុះបញ្ចាំងនូវការរាយការណ៍តែភាគីម្ខាងដែលធ្វើឱ្យមានការភាន់ច្រឡំ និងមានព័ត៌មានមិនពិតជាច្រើន។ សូម្បីតែបន្ទាប់ពីមានបទឈប់បាញ់បានឈានដល់ការព្រមព្រៀងគ្នារវាងប្រទេសទាំងពីរក៏ដោយ ប៉ុន្តែការរាយការណ៍ដែលមានភាពលំអៀងនៃភាគីម្ខាង និងភាគីម្ខាងទៀតនៅតែបន្ត នឹងបង្កឱ្យមានការយល់ច្រឡំនិងការស្អប់ខ្ពើម។

យើងខ្ញុំសូមអំពាវនាវបន្ថែមទៀតដល់អ្នកសារព័ត៌មានទាំងអស់ មិនថាក្នុងស្រុក ឬអន្តរជាតិ ទាំងនៅប្រទេសកម្ពុជា ឬនៅប្រទេសថៃ អ្នកសារព័ត៌មានវិជ្ជាជីវៈ ឬពលរដ្ឋ ត្រូវប្រកាន់យ៉ាងម៉ឺងម៉ាត់ នូវក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ដែលត្រូវបានទទួលស្គាល់ជាសាកល ជាពិសេសនៅពេលរាយការណ៍ អំពីបញ្ហាព្រំដែនដ៏រសើប។ សារព័ត៌មានប្រកបដោយ ក្រមសីលធម៌វិជ្ជាជីវៈ ទាមទារភាពត្រឹមត្រូវ យុត្តិធម៌ និងកិច្ចខិតខំប្រឹងប្រែងប្រកបដោយមនសិការ ដើម្បីជៀស វាងការភាន់ច្រឡំ ឬការបង្កើននូវជម្លោះបន្ថែមទៀត។

ក្នុងស្ថានភាពតានតឹង និងភាពមិនប្រាកដប្រជា សារព័ត៌មានដែលមានការទទួលខុសត្រូវ មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតការយល់ដឹងជាសាធារណៈ និងលើកកម្ពស់សន្តិភាព។ ដូច្នេះ ការដែលភាគីពាក់ព័ន្ធទាំងអស់ រួមទាំងរដ្ឋាភិបាល ភ្នាក់ងារសារព័ត៌មាន និងអ្នកសារព័ត៌មាន ត្រូវលើកកម្ពស់ ការទទួលខុសត្រូវរៀងៗខ្លួនក្នុងការការពារអ្នកសារព័ត៌មាន និងធានាការផ្សាយព័ត៌មានប្រកបដោយយុត្តិធម៌ ពិតប្រាកដ និងក្រមសីលធម៌វិជ្ជាជីវៈ ពិតជាមានសារៈសំខាន់ខ្លាំងណាស់។

**សេចក្តីថ្លែងការណ៍នេះត្រូវបានគាំទ្ររួមគ្នាដោយ៖**

1. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
2. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)
3. អង្គការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (CMPO)
4. មជ្ឈមណ្ឌដើម្បីសារព័ត៌មានឯករាជ្យ (CIJ)
5. សហភាពជាតិអ្នកកាសែតហ្វីលីពីន (NUJP)
6. សម្ព័ន្ធអ្នកកាសែតឯករាជ្យ (AJI)
7. Gerakan Media Merdek (Geramm)
8. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ស៊ីស៊ីអាយអឹម)
9. ក្លឹបអ្នកសារព័ត៌មានក្រៅប្រទេសកម្ពុជា (OPCC)
10. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់)
11. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)
12. Prachatai
13. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)
14. អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF)
15. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
16. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)